# មេរៀនទី៣៥៖ ព្រះការពារលោកម៉ូសេ

## និក្ខមនំ ១៖១-២៖១០

**មេរៀនសម្រាប់គ្រូ** *( យូធូបលីង )*៖ https://youtu.be/sHMC0XX6u-0

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/h4lqAOyGzv4

**គោលបំណង៖** ព្រះតែងតែការពារយើង

**ខគម្ពីរចងចាំ៖** ***ទំនុកដំកើង ៤៦៖១*** *"ព្រះទ្រង់ជាទីពឹងជ្រក ក៏ជាកំឡាំងនៃយើងខ្ញុំ ជាជំនួយដែលនៅជាប់ជាមួយក្នុងគ្រាអាសន្ន"។*

**ចំរៀង** *( យូធូបលីង )*៖

១. កូនតូចៗអើយ https://youtu.be/ewu6Tfpo5Vo
២. ព្រះអង្គនៃយើងទ្រង់ខ្លាំងពូកែ https://youtu.be/VvrF94VKKHA
៣. ពេលខ្យល់ព្យុះបក់ខ្លាំង https://youtu.be/lI5A7jKQb2o

## ១. អធិស្ឋាន

កូនសូមអរព្រះគុណ ដែលទ្រង់ជាព្រះដ៏ល្អ។ កូនសូមអរគុណទ្រង់សម្រាប់សេចក្ដីស្រឡាញ់ដ៏អស្ចារ្យដែលកូនមិនអាចវាស់បាន។ សូមអរព្រះគុណទ្រង់សម្រាប់ការការពារ តម្រង់ផ្លូវ និង មើលថែកូនគ្រប់ពេលវេលាទាំងអស់។ សូមជួយកូនឲ្យជឿ និងទុកចិត្តដល់ទ្រង់។ កូនស្រឡាញ់ព្រះអង្គ! អាម៉ែន

## ២. ចំរៀង

*សូមច្រៀងចម្រៀងដែលមានលីង នៅក្នុងយូធូបលីងខាងលើ*

## ៣. ល្បែងកំសាន្ត "រាប់សរសៃសក់"



១ .តើអ្នកគិតថានៅលើក្បាលរបស់អ្នកមានសក់ប៉ុន្មានសរសៃ? តើធ្វើដូចម្ដេចទើបអាចដឹងថាយើង មានសក់ ប៉ុន្មានសរសៃនោះ? យើងអាចរាប់វាបាន! អញ្ចឹងតោះ! យើងរាប់ទាំងអស់គ្នា។ អ្នកណាដែលអាចរាប់ សរសៃសក់បាននឹងឈ្នះ!

- ឲ្យសិស្សចាប់ដៃគូ រួចឲ្យពួកគេព្យាយាមរាប់សក់ឲ្យគ្នាទៅវិញទៅមក។

២ .ប្រហែលជា ១នាទី គ្រូសួរទៅកាន់សិស្ស ក្រែងលោមានសិស្សខ្លះអាចរាប់សរសៃសក់អស់។ វាមិន អាចទៅរួចទេក្នុងការដែលរាប់សរសៃសក់ អស់នោះទាល់តែប្រើពេលយូរខ្លាំងណាស់ទើប អាចរាប់បាន។

៣. ប៉ុន្តែអ្វីដែលជារឿងដ៏អស្ចារ្យនោះគឺព្រះទ្រង់ដឹងច្បាស់ថាមនុស្សម្នាក់ៗ នៅលើផែនដីនេះមានសក់ប៉ុន្មានសរសៃ ព្រះរបស់យើងទ្រង់អស្ចារ្យណាស់។

## ៤. ការណែនាំមេរៀន

ព្រះរបស់យើងទ្រង់ជ្រាបគ្រប់រឿងទាំងអស់ ទ្រង់ទតមើលយើងដោយការការពារ ដឹកនាំ ប្រទានពរហើយជួយដល់យើង។ ព្រះអង្គធ្វើដូច្នេះព្រោះទ្រង់ស្រលាញ់យើង។ ទ្រង់កំពុងធ្វើការ ជាច្រើននៅគ្រប់ទីន្លែងក្នុងផែនដីនេះ។ ព្រះអង្គមិនមែនគ្រាន់តែទតមើលយើងដែលកំពុងនៅក្នុងថ្នាក់រៀននេះទេ ទ្រង់ក៏កំពុងតែទតមើលមកមនុស្សគ្រប់គ្នានៅលើផែនដីនេះដែរ។ ព្រះអង្គមើលថែកូននៅថ្ងៃនេះ! ព្រះស្រឡាញ់កូន ហើយទ្រង់ខ្វល់ខ្វាយពីរឿងគ្រប់យ៉ាងដែលកូនធ្វើមិនថាការនោះតូចឬធំនោះទេ សូម្បីតែពេលកូនកំពុងដុសធ្មេញ ឬកំពុងលេងជាមួយមិត្តភក្ដិ ឬក៏ពេលកូនកំពុងប្រលងនៅក្នុងសាលាក៏ដោយ។ ព្រះអង្គមិនដែលឈប់ទតមើលមកកូនៗនោះទេ។ សាច់រឿងនៅក្នុងព្រះគម្ពីរថ្ងៃនេះ បង្ហាញយើងពីរបៀបដែលព្រះទ្រង់ទតមើលមក

យើងទោះបីជាក្នុងពេលដែលយើងជួបទុក្ខលំបាកក៏ដោយ។ ព្រះគម្ពីរនិក្ខមនំ ១:១-២:១០ គឺនិយាយអំពីគ្រាដ៏លំបាកក្នុងជីវិតរបស់ម៉ូសេតាំងពីគាត់នៅជាកូនង៉ានៅឡើយ។ ដែលនៅពេលនោះរាស្ត្ររបស់ព្រះជួបទុក្ខលំបាកជាខ្លាំង! យើងនឹងស្វែងយល់ជាមួយគ្នាពីរបៀបដែលព្រះអង្គបានការពារលោកម៉ូសេ។

## ៥. រឿងក្នុងព្រះគម្ពីរ

នៅក្នុងព្រះគម្ពីរនិក្ខមនំបង្ហាញថាប្រជាជនអ៊ីស្រាអែលបានជួបទុក្ខលំបាកដ៏ធំមួយ។ ផារ៉ោនជាស្តេច អេ-ហ្ស៊ីប្របានមើលឃើញថា មានប្រជាជនអ៊ីស្រាអែលជាច្រើនកំពុងរស់នៅលើទឹកដីរបស់គាត់។ ស្តេចផារ៉ោន ជឿថាប្រជាជនអ៊ីស្រាអែលនឹងងើបឡើងប្រឆាំង ហើយគ្រប់គ្រងលើទឹកដីរបស់គាត់។ ដូច្នេះគាត់ក៏បានប្រាប់ទៅឆ្មបទាំងអស់ថា ពេលទៅសម្រាលកូន បើឃើញទារកដែលជាកូនរបស់ជនជាតិ អ៊ីស្រា-អែលជាកូនប្រុស ត្រូវតែសម្លាប់ចោលទាំងអស់។ តើកូនគិត ថាឆ្មបទាំងនោះធ្វើតាមបង្គាប់ ស្តេចផារ៉ោនដែរឬទេ? អត់ទេ! ព្រោះពួកគាត់ទាំងនោះកោតខ្លាចព្រះ ពួកគាត់មិនចង់ មានបញ្ហាធំជាមួយនឹងព្រះទេ។ នេះជារឿងល្អសម្រាប់លោកម៉ូសេ ពីព្រោះនៅពេលដែលគាត់ចាប់កំណើត ម្តាយរបស់គាត់ បានព្យាយាមលាក់គាត់មិនឲ្យស្តេចផារ៉ោនដឹង រហូតដល់គាត់មិនអាចលាក់បន្តទៀតបាន។

ដូច្នេះ ហើយ ម្តាយម៉ូសេបានយកគាត់ទៅដាក់ក្នុងកន្ត្រកមួយដែលមិនអាចលេចទឹក ហើយដាក់បណ្តែតទៅក្នុងទន្លេ។ ម្តាយម៉ូសេដឹងច្បាស់ថា ព្រះនឹងតាមមើលថែម៉ូសេ ហើយព្រះអង្គបានធ្វើ ដូច្នេះមែន! បុត្រីរបស់ផារ៉ោន ដែលជាព្រះនាងនៃប្រទេសអេហ្ស៊ីប្របានឃើញម៉ូសេ ហើយក៏យកម៉ូសេមកចិញ្ចឹមធ្វើជាកូនប្រុសរបស់ គាត់នៅក្នុងរាជវាំង។

## ៦. សំនួរពិភាក្សា

១. តើស្តេចអេហ្ស៊ីប្រឈ្មោះអ្វី? *(ផារ៉ោន)*
២. តើផារ៉ោនបានធ្វើអ្វីដាក់ជនជាតិអ៊ីស្រាអែល? *(សំឡាប់កូនក្មេងប្រុសៗទាំងអស់)*
៣. តើម្តាយម៉ូសេព្យាយាមប្រើវិធីអ្វីដើម្បីសង្គ្រោះម៉ូសេ? *(គាត់ដាក់ម៉ូសេនៅក្នុងកន្ត្រក ហើយគាត់អធិស្ឋានសុំឲ្យព្រះអង្គតាមការពារម៉ូសេ)*
៤. តើព្រះការពារម៉ូសេដោយរបៀបណា? *(បុត្រីស្តេចផារ៉ោន)*
៥. តើប្អូនៗដឹងថាព្រះជួយប្អូនៗដោយរបៀបណា? *(សូមឲ្យកុមារឆ្លើយ)*

## ៧. ល្បែងកំសាន្ត *"ល្បែងឧបសគ្គ"*



១ .ម៉ូសេមានឧបសគ្គជាច្រើននៅក្នុងជីវិតរបស់គាត់ប៉ុន្តែព្រះបានដឹងពីបញ្ហារបស់ម៉ូសេហើយបានជួយគាត់។
២. ចែកកុមារជា២ក្រុម ហើយរៀបចំឲ្យមានឧបសគ្គជាច្រើននៅក្នុងថ្នាក់រៀន ដោយប្រើកៅអី ឬ របស់ ក្មេងលេងជាដើម
៣. យកក្រណាត់មកចងបិទភ្នែកក្រុមទី១ ហើយឲ្យគេដើរឆ្លងកាត់បន្ទប់ដោយមិនឲ្យប៉ះនូវ ឧបសគ្គ ណាមួយឡើយ។ ពួកគេអាចមើលឃើញពីទីតាំងរបស់ឧបសគ្គទាំងនោះហើយត្រូវរកវិធីធ្វើយ៉ាងណាដើម្បីកុំឲ្យប៉ះ ឧបសគ្គពេលគេដើរឆ្លងកាត់។
៤. នៅពេលដែលក្រុមទី១ កំពុងត្រូវបានគេចងបិទ ភ្នែក ក្រុមទី២ ត្រូវយកឧបសគ្គចេញដោយស្ងៀមស្ងាត់ (*កុំឲ្យលឺសម្លេង*)
៥. គ្រូប្រាប់ក្រុមទី ១ ឲ្យដើរឆ្លងកាត់បន្ទប់ដោយមិនឲ្យប៉ះឧបសគ្គ (*ប៉ុន្តែមិនមានឧបសគ្គទេ នៅក្នុង បន្ទប់*) ។
៦. នៅពេលក្រុមទី ១ ទៅដល់ទីម្ខាងទៀតសូមឲ្យក្មេងៗស្រាយក្រណាត់រុំភ្នែកចេញ។



៧. ពួកគេនឹង ឃើញថាគ្មានឧបសគ្គនៅក្នុងផ្លូវរបស់ពួកគេទេ។

៨. ពេលខ្លះជីវិតរបស់យើងក៏ស្រដៀងគ្នាដែរ វាហាក់ដូចជាមានឧបសគ្គនិងរឿងលំបាកជាច្រើននៅក្នុង

ជីវិត របស់យើង។ ប៉ុន្តែបើយើងទុកចិត្តព្រះឲ្យទ្រង់មើលថែយើង នោះយើងនឹងឃើញថា ទ្រង់ជួយយើង ឲ្យឆ្លង កាត់ឧបសគ្គឬក៏ដកហូតយកឧបសគ្គទាំងនោះចេញតែម្តង។

### ៨. ខគម្ពីរចងចាំ

***ទំនុកដំកើង ៤៦:១*** *"ព្រះទ្រង់ជាទីពឹងជ្រក ក៏ជាកំឡាំងនៃយើងខ្ញុំ ជាជំនួយដែលនៅជាប់ ជាមួយក្នុងគ្រាអាសន្ន"*។

សូមជួយកុមារឲ្យចងចាំខគម្ពីរនេះដោយប្រើកាយវិកា។

### ៩. ហាត្ថកម្ម

សូមផាត់ពណ៌រូបភាពនៅទំព័រខាងក្រោម

### ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ១១. អធិស្ឋាន

ព្រះជាម្ចាស់ កូនអរព្រះគុណទ្រង់សំរាប់ការទតរំពៃមើលថែកូន ហើយការពារកូន សូមព្រះអង្គជួយកូន ឲ្យទុកចិត្តទ្រង់គ្រប់ពេល កូនសូមអធិស្ឋាននៅក្នុងព្រះនាមព្រះអង្គម្ចាស់ព្រះយេស៊ូវគ្រីស្ទ អាម៉ែន!

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ជីវិតអាចនឹងពិបាក និងអាចមានគ្រោះថ្នាក់។ ព្រះនឹងការពារមនុស្សគ្រប់គ្នាដែលទុកចិត្ត និងដើរតាមព្រះរាជបុត្រារបស់ព្រះអង្គគឺព្រះយេស៊ូវគ្រីស្ទ។ នៅពេលដែលជីវិតម៉ូសេជួបការគំរាមកំហែង ព្រះបានការពារគាត់ដោយបែបច្នៃប្រឌិតដ៏ល្អបំផុត។ តើយើងអាចនឹងរំលឹកឡើងវិញពីការការពារដ៏អស្ចារ្យរបស់ព្រះដែលយើងមើលមិនឃើញនៅក្នុងជីវិតរបស់យើង ឬក៏នៅក្នុងជីវិតរបស់នរណាម្នាក់បានទេ? ថ្ងៃនេះ សូមអរព្រះគុណព្រះសំរាប់ក្តីស្រលាញ់ និងការការពារមើលថែអ្នក កូនសិស្សរបស់អ្នក និងមនុស្សដែលអ្នកស្រលាញ់។

